Seattle

EQUITY & ENVIRONMENT INITIATIVE

**The Environmental Justice Fund 2019**

A program of the City of Seattle. Administered by The Bullitt Foundation.

យើងមានសេចក្តីរំភើបរីករាយ សូមប្រកាសអំពីជុំទីពីរនៃមូលនិធិយុត្តិធម៌បរិស្ថាន (Environmental Justice Fund) ដែលជាឱកាសផ្តល់មូលនិធិជំនួយសម្រាប់គម្រោងដែលដឹកនាំដោយសហគមន៍ ដែលវិនិយោគលើសមត្ថភាពសហគមន៍ដើម្បីកែលម្អដល់ស្ថានភាពបរិស្ថាន និងឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

មូលនិធិនេះត្រូវបានសហការបង្កើតឡើងដោយគណៈកម្មការយុត្តិធម៌បរិស្ថាន (Environmental Justice Committee) – បុគ្គលិក 12 រូប ដែលមានឫសគល់សហគមន៍យ៉ាងជ្រៅ ដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ ទៅលើបញ្ហាយុត្តិធម៌បរិស្ថាន - ដោយមានការគាំទ្រពីការិយាល័យនិរន្តរភាព និងបរិស្ថានក្រុងស៊ីអាថល (Seattle Office of Sustainability & Environment)។

មូលនិធិនេះទទួលស្គាល់ថា ដំណោះស្រាយបរិស្ថាន និងអាកាសធាតុដ៏មានប្រសិទ្ធិភាពបំផុត បានមកពីសហគមន៍ខ្លួនឯងផ្ទាល់ និងទទួលស្គាល់ថា សមាជិកនានារបស់សហគមន៍មានតួនាទីល្អបំផុតនៅក្នុងការបង្កើត និងអនុវត្តគម្រោងនានា ដែលរួមមានផ្នែកសហគមន៍ វប្បធម៌ ធម្មជាតិ គ្រួសារ សុខភាព ស្បៀងអាហារ និង/ឬការអប់រំ។

អង្គការដែលដឹកនាំដោយសហគមន៍ និងប្រជាពលរដ្ឋដែលមិនមែនជាជនជាតិស្បែកស ត្រូវបានអញ្ជើញឲ្យដាក់ សំណើសុំសម្រាប់គម្រោង។ គម្រោងគួរត្រូវបានដឹកនាំដោយប្រជាពលរដ្ឋ និងបម្រើប្រយោជន៍ដល់ប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់ពីបញ្ហាទាំងនេះ៖ សហគមន៍មិនមែនជនជាតិស្បែកស ជនអន្តោប្រវេសន៍ ជនភៀសខ្លួន និងប្រជាពលរដ្ឋម្ចាស់ស្រុក - រួមមាន ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប យុវជន និងប្រជាពលរដ្ឋវ័យចំណាស់ - ដែលរស់នៅ សិក្សា ធ្វើការងារ គោរពបូជា និងលេងកម្សាន្តនៅទីក្រុងស៊ីអាថល (City of Seattle)។

មានការផ្តល់មូលនិធិចំនួន $200,000 ដែលអាចទទួលបានពីទីក្រុងស៊ីអាថល (City of Seattle) ជាមួយនឹងថវិកាមូលនិធិ ដែលគ្រប់គ្រងដោយមូលនិធិ Bullitt។ ការផ្តល់មូលនិធិជំនួយអតិបរមា នឹងមានចំនួន $40,000។ គម្រោងនានា នឹងចាប់ផ្តើមនៅខែមករា ឆ្នាំ 2020 ហើយត្រូវតែបញ្ចប់នៅត្រឹមខែមិថុនា ឆ្នាំ 2021។ សំណើសុំនឹងផុតកំណត់នៅត្រឹម ម៉ោង **4 រសៀល នៅថ្ងៃច័ន្ទ ទី 16 ខែកញ្ញា ឆ្នាំ 2019។**

កិច្ចប្រជុំផ្តល់ព័ត៌មាន និងជំនួយដោយផ្ទាល់ នឹងត្រូវផ្តល់ជូនដើម្បីជួយសម្រួលដល់បេក្ខជនជាមួយនឹងដំណើរការ។
ព័ត៌មានលម្អិតបន្ថែមទៀតអាចរកបានតាមប្រព័ន្ធអនឡាញ តាមរយៈ: seattle.gov/environment/ejfund
មានសំណួរដែរឬទេ? សូមអ៊ីម៉ែលមកកាន់៖ ejfrfp@gmail.com

សូមកត់សម្គាល់ថារាល់ឯកសារសំណើដែលបានសរសេរទាំងអស់ត្រូវតែដាក់បញ្ជូនជាអង់គ្លេស